ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៥៦ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ពន្ធលើចំណេញមូលធន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ ..**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាន និងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន។

**ប្រការ២ ..**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធនិវាសនជនជារូបវន្តបុគ្គលដែលសម្រេចបានចំណេញមូលធនពីការលក់ឬផ្ទេរចំពោះមូលធនដែលស្ថិតនៅព្រះរាជាណាចក្រកម្ពុជានិងនៅបរទេស និងអ្នកជាប់ពន្ធអនិវាសនជន ដែលសម្រេចបានចំណេញមូលធនពីការលក់ឬផ្ទេរចំពោះមូលធនដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ..**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- អ្នកជាប់ពន្ធ សំដៅដល់ អ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជន ដែលបានលក់ឬផ្ទេរមូលធនទៅឱ្យបុគ្គលដទៃ។

២- អ្នកជាប់ពន្ធនិវាសនជន សំដៅដល់រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ (មួយរយប៉ែតសិបពីរ) ថ្ងៃ ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

៣- អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤- មូលធន សំដៅដល់ទ្រព្យចំនួន ៦ (ប្រាំមួយ) ប្រភេទ រួមមាន អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

- ក- អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ។
- ខ- ភតិសន្យា សំដៅដល់ ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់និងប្រើប្រាស់អចលនវត្ថុក្នុងរយៈពេលមួយដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬតាមតម្លៃសមមូល។ ភតិសន្យារួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ វៀរលែងតែភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុ និងភតិសន្យាពិសេសដែលមានចែងក្នុងច្បាប់ស្តីពីភតិសន្យាពិសេស។ ភតិសន្យាបន្ត សំដៅដល់ប្រតិបត្តិការដែលអចលនវត្ថុ ត្រូវបានជួលដោយភតិកៈដំបូងត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូងនៅមានសុពលភាពដដែល។

គ-ទ្រព្យវិនិយោគ សំដៅដល់ ទ្រព្យទាំងឡាយរួមមាន ភាគហ៊ុន សញ្ញាបណ្ណ មូលបត្រ និងទ្រព្យហិរញ្ញវត្ថុផ្សេងទៀត។

ភាគហ៊ុន សំដៅដល់ ចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬការលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហគ្រាសឯកបុគ្គលដែលបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ-កេរ្តិ៍ឈ្មោះអាជីវកម្ម សំដៅដល់ ទ្រព្យអរូបី ជាអាទិ៍មានអាជ្ញាបណ្ណ បញ្ជីឈ្មោះអតិថិជន និងយីហោ។

ង-កម្មសិទ្ធិបញ្ញា មានជាអាទិ៍ តក្កកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ម៉ាក ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម។

ច-រូបិយបណ្ណបរទេស សំដៅដល់ រូបិយបណ្ណក្រៅពីប្រាក់រៀល។

៥- ចំណេញមូលធន សំដៅដល់ ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត។

៦- ប្រទានកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៧- សន្តតិកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិតាមរយៈ៖

ក- បណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬ

ខ- ការបញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ

គ- សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់។

**ប្រការ៤ .-**

សម្រាប់គោលដៅនៃប្រកាសនេះ អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធន នៅពេល៖

១- លក់ឬផ្ទេរ ឬបង្កើតឱ្យមានសិទ្ធិគ្រប់គ្រងលើទ្រព្យ ឬ

២- ចុះបញ្ជីសម្រាប់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យនៅអាជ្ញាធរមានសមត្ថកិច្ច ឬ

៣- ពេលសម្រេចផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

ដោយឡែក ចំពោះទ្រព្យជាភាគហ៊ុន អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធន នៅពេលមុនគេណាមួយនៅក្នុងចំណោម៖

១- ការទទួលស្គាល់ការផ្ទេរភាគហ៊ុនដោយក្រសួងពាណិជ្ជកម្ម។

២- ការបាត់បង់សិទ្ធិគ្រប់គ្រងភាគហ៊ុនរបស់ម្ចាស់ភាគហ៊ុនដែលបានលក់ឬផ្ទេរ។

៣- បានទូទាត់គ្រប់ចំនួននូវតម្លៃភាគហ៊ុនដែលបានលក់ឬផ្ទេរ។

**ប្រការ៥ .-**

អត្រាពន្ធលើចំណេញមូលធន ត្រូវបានកំណត់តាមអត្រា ២០ (ម្ភៃ) ភាគរយនៃចំណេញមូលធន។

**ប្រការ៦ ..**

១- ពន្ធលើចំណេញមូលធន ត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរៈ

ក- ដីកសិកម្មជាកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដែលប្រជាពលរដ្ឋកំពុងបង្កបង្កើនផលពិតប្រាកដដោយត្រូវភ្ជាប់លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់អំពីការប្រើប្រាស់ដីធ្លីកសិកម្មពីអាជ្ញាធរមូលដ្ឋាន ឬរដ្ឋបាលសារពើពន្ធ។

ខ- និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់យ៉ាងតិចរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនពេលលក់ឬផ្ទេរ។ ក្នុងករណីអ្នកជាប់ពន្ធមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានជាគោលដើម។

គ- អចលនទ្រព្យក្នុងរង្វង់ញាតិតាមរយៈការធ្វើសន្តតិកម្ម រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយតាបង្កើតនិងចៅបង្កើត រវាងឪពុកម្តាយនិងកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះ ដើម្បីជាទ្រព្យសម្បត្តិរួម និងរវាងយាយតានិងចៅបង្កើតនិងចៅប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះ ដើម្បីជាទ្រព្យសម្បត្តិរួម។

ឃ- អចលនទ្រព្យក្នុងរង្វង់ញាតិតាមរយៈការធ្វើប្រទានកម្មលើកទី១ រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយតាបង្កើតនិងចៅបង្កើត រវាងឪពុកម្តាយនិងកូនបង្កើតនិងកូនប្រសារដែលជាសហព័ទ្ធរបស់កូនបង្កើតនោះ ដើម្បីជាទ្រព្យសម្បត្តិរួម និងរវាងយាយតានិងចៅបង្កើតនិងចៅប្រសារដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះ ដើម្បីជាទ្រព្យសម្បត្តិរួម។

ង- ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ។

ច- ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ។

ឆ- ទ្រព្យសម្រាប់បម្រើប្រយោជន៍សាធារណៈ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

២- ការបោះចេញភាគហ៊ុនថ្មីក្នុងគោលដៅបង្កើនដើមទុន ឬដាក់ទុនវិនិយោគថ្មីសុទ្ធសាធនៅក្នុងក្រុមហ៊ុន មិនត្រូវចាត់ទុកជាការលក់ឬផ្ទេរភាគហ៊ុនដែលជាកម្មវត្ថុនៃពន្ធលើចំណេញមូលធនឡើយ។ ករណីនេះ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនថ្មី ត្រូវបង់ប្រាក់ចំណែកភាគហ៊ុនថ្មីចូលក្នុងក្រុមហ៊ុនទាំងស្រុងដោយផ្អែកតាមតម្លៃនៃកិច្ចព្រមព្រៀងកាន់កាប់ភាគហ៊ុនថ្មី ហើយគ្មានភាគហ៊ុនិកណាម្នាក់ទទួលបានផលប្រយោជន៍ពីអ្នកកាន់កាប់ភាគហ៊ុនថ្មី។

៣- ករណី មានការលក់ឬផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនក្នុងដើមទុន ឬមូលធនរបស់សហគ្រាសដែលមានប្រាក់ចំណូលរក្សាទុក អ្នកជាប់ពន្ធអនិវាសនជនដែលមានកាតព្វកិច្ចបង់ពន្ធលើចំណេញមូលធន នឹងត្រូវបានលើកលែងពន្ធកាត់ទុកលើការបែងចែកភាគលាភ។

៤- អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធនដែលជាកម្មវត្ថុពន្ធលើចំណេញមូលធន ត្រូវបានលើកលែងពន្ធកាត់ទុកចំពោះការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជា តាមមាត្រា៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ៧ ..**

ចំណាយដែលអនុញ្ញាតឱ្យកាត់កងបាន ត្រូវបំពេញនូវលក្ខខណ្ឌទាំងបីដូចខាងក្រោម៖

១- ហេតុការណ៍ដែលអាចបញ្ជាក់អំពីការកើតឡើងនូវបន្ទុក ឬចំណាយ ដែលមានភស្តុតាងអាចត្រួតពិនិត្យបាន។

២- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិននឹងចំណាយ។

៣- មានវិក្កយបត្រ ឬឯកសារភស្តុតាងបញ្ជាក់អំពីចំនួនទឹកប្រាក់និងកាលបរិច្ឆេទដែលបានចំណាយ។

**ប្រការ៨ ..**

វិធាននៃការកាត់កងចំណាយ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះមូលធនជាអចលនទ្រព្យ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីទាំងពីរដូចខាងក្រោម៖

ក- វិធីកាត់កងចំណាយតាមការកំណត់៖ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយ ៨០ (ប៉ែតសិប) ភាគរយ នៃប្រាក់ចំណូលដែលទទួលបានពីការលក់ឬផ្ទេរទ្រព្យ។

ខ- វិធីកាត់កងតាមចំណាយជាក់ស្តែង៖ ត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងចំណាយដែលបានកើតឡើងជាក់ស្តែង។

២- ចំពោះមូលធនដទៃទៀត អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយ តែតាមវិធីកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធជ្រើសរើសវិធីកាត់កងតាមចំណាយជាក់ស្តែង ហើយចំណាយដែលបានកើតឡើងជាក់ស្តែងមានចំនួនច្រើនជាងចំណូលពីការលក់ឬផ្ទេរទ្រព្យ ចំនួនលើសមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបង្វិលសង ឬយកទៅកាត់កងចេញពីចំណេញមូលធននៃទ្រព្យដទៃទៀតទេ។

**ប្រការ៩ ..**

ដើម្បីគណនាពន្ធលើចំណេញមូលធនក្រៅពីភាគហ៊ុន ថ្លៃលក់ និងចំណាយដែលអនុញ្ញាតឱ្យកាត់កងបាននៃទ្រព្យត្រូវកំណត់ដូចខាងក្រោម៖

១- ថ្លៃលក់នៃទ្រព្យ ត្រូវគិតតាមតម្លៃលក់ឬផ្ទេរទ្រព្យដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាទិញ-លក់ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធរកឃើញថាថ្លៃលក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាទិញ-លក់មិនឆ្លុះបញ្ចាំងពីតម្លៃពិត រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវថ្លៃលក់នៃទ្រព្យដោយឈរលើតម្លៃមួយណាដែលខ្ពស់ជាងនៃតម្លៃពិតក្នុងកិច្ចសន្យាពិតដែលរដ្ឋបាលសារពើពន្ធរកឃើញ ឬតម្លៃដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬតម្លៃដែលកំណត់ដោយគណៈកម្មការវាយតម្លៃទ្រព្យនៃពន្ធលើចំណេញមូលធន។

២- ចំណាយដែលអនុញ្ញាតឱ្យកាត់កងបាននៃទ្រព្យ រួមមាន ថ្លៃដើមពេលទិញទ្រព្យ និងចំណាយដែលបានកើតឡើងក្នុងពេលទិញឬទទួលកាន់កាប់លក់ឬផ្ទេរទ្រព្យ ស្របតាមប្រការ៧ នៃប្រកាសនេះ ដែលជាអាទិ៍មាន៖

ក- ចំណាយលើសេវាពិគ្រោះយោបល់។

ខ- ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់នៅពេលទិញឬទទួលទ្រព្យ។

គ- ប្រាក់ពន្ធលើអចលនទ្រព្យ ឬប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ដែលបានបង់។

ឃ-ចំណាយលើសេវារដ្ឋបាលសុរិយោដីឬភូមិបាល។

ង- ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម។

ច- ចំណាយកម្រៃជើងសា។

ឆ- ចំណាយលើការវាយតម្លៃទ្រព្យ។

ជ- ចំណាយលើសេវារដ្ឋបាលចំពោះការខ្ចីប្រាក់ដើម្បីទិញឬទទួលទ្រព្យ។

ឈ-ចំណាយការប្រាក់ចំពោះការខ្ចីប្រាក់ដើម្បីទិញទ្រព្យដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ។

ញ-ចំណាយថែទាំនិងកែលម្អទ្រព្យ។

ដ- ចំណាយក្នុងការបង្កើតឬរក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ។

ឋ- ចំណាយពាក់ព័ន្ធដោយផ្ទាល់ផ្សេងៗទៀត។

**ប្រការ១០ ..**

ដើម្បីគណនាពន្ធលើចំណេញមូលធនសម្រាប់ភាគហ៊ុន ថ្លៃលក់ឬផ្ទេរនិងចំណាយដែលអនុញ្ញាតឱ្យកាត់កងបាននៃភាគហ៊ុនត្រូវកំណត់ដូចខាងក្រោម៖

១- ថ្លៃលក់ឬផ្ទេរភាគហ៊ុន ត្រូវគិតតាមតម្លៃលក់ឬផ្ទេរភាគហ៊ុន ដែលមានចែងក្នុងកិច្ចសន្យាទិញ-លក់ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗទៀតប្រសិនបើមាន។ សម្រាប់គោលដៅនៃប្រការនេះការលក់ឬផ្ទេរភាគហ៊ុន សំដៅដល់ ប្រតិបត្តិការឬព្រឹត្តិការណ៍គ្រប់ប្រភេទដែលបានកើតឡើង ដែលធ្វើឱ្យអ្នកជាប់ពន្ធបាត់បង់នូវសិទ្ធិ ការគ្រប់គ្រងឬការចាត់ចែង ទៅលើចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន។ ប្រតិបត្តិការឬព្រឹត្តិការណ៍ទាំងនោះ មានជាអាទិ៍ ការលក់ឬផ្ទេរ ការដកហូតតាមផ្លូវច្បាប់ ការដោះដូរ ការផ្តល់ជាអំណោយ ការដកចេញ ការបញ្ចប់អាជីវកម្មរបស់សហគ្រាស។

ប្រតិបត្តិការឬព្រឹត្តិការណ៍ដូចជា ការផ្តល់ជាអំណោយ ការដកចេញ ឬការបញ្ចប់អាជីវកម្មរបស់សហគ្រាស ដែលត្រូវបានចាត់ទុកថាលក់ឬផ្ទេរប៉ុន្តែពុំមានកិច្ចសន្យា ប្រតិបត្តិការឬព្រឹត្តិការណ៍ទាំងនេះគឺត្រូវគិតទៅតាមតម្លៃទីផ្សារ ។

២- ចំណាយដែលអនុញ្ញាតឱ្យកាត់កងបាននៃភាគហ៊ុន រួមមាន ដើមទុនឬមូលធនភាគហ៊ុនបានបង់ ឬថ្លៃដើមពេលទិញភាគហ៊ុនក្នុងអំឡុងពេលបើកអាជីវកម្ម ឬដំឡើងដើមទុន និងចំណាយទាក់ទងនឹងប្រតិបត្តិការលក់ឬផ្ទេរ មានជាអាទិ៍ ចំណាយលើសេវាពិគ្រោះយោបល់ ចំណាយលើកម្រៃជើងសា ចំណាយលើការវាយតម្លៃភាគហ៊ុន និងចំណាយពាក់ព័ន្ធដោយផ្ទាល់ផ្សេងៗទៀត ស្របតាមប្រការ៧ នៃប្រកាសនេះ។

**ប្រការ១១ ..**

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធន តាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី ៣ (បី) ខែ បន្ទាប់ពីសម្រេចបានចំណេញមូលធនដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។

១- ចំពោះទ្រព្យក្រៅពីភាគហ៊ុនដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ចំពោះទ្រព្យក្រៅពីភាគហ៊ុនដែលស្ថិតនៅតាមបណ្តាខេត្ត អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅសាខាពន្ធដារខេត្តដែលទ្រព្យនោះស្ថិតនៅ ឬនៅអគ្គនាយកដ្ឋានពន្ធដារតាមការស្នើសុំរបស់អ្នកជាប់ពន្ធ។

២- ចំពោះសហគ្រាសដែលមានម្ចាស់ភាគហ៊ុនធ្វើការលក់ឬផ្ទេរភាគហ៊ុន សហគ្រាសនោះត្រូវមានកាតព្វកិច្ចកាត់ទុក និងប្រកាសបង់ពន្ធលើចំណេញមូលធនពីការលក់ឬផ្ទេរភាគហ៊ុននោះជូនរដ្ឋបាលសារពើពន្ធ។

៣- ចំពោះការលក់ឬផ្ទេរទ្រព្យវិនិយោគជាមូលបត្រដែលបានចុះបញ្ជីជួញដូរក្នុងទីផ្សារមូលបត្រកម្ពុជា បុគ្គលជាភ្នាក់ងារទូទាត់ ត្រូវមានកាតព្វកិច្ចកាត់ទុក និងប្រកាសបង់ពន្ធលើចំណេញមូលធនជូនរដ្ឋបាលសារពើពន្ធ។

៤- ចំពោះប្រតិបត្តិការជួញដូររូបិយបណ្ណបរទេស និងទ្រព្យហិរញ្ញវត្ថុផ្សេងទៀត ដែលធ្វើឡើងដោយបុគ្គលជួញដូរតាមរយៈសហគ្រាសដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា បុគ្គលជាភ្នាក់ងារទូទាត់ត្រូវមានកាតព្វកិច្ចកាត់ទុក និងប្រកាសបង់ពន្ធលើចំណេញមូលធនជូនរដ្ឋបាលសារពើពន្ធ។

**ប្រការ១២ ..**

ក្នុងករណីដែលអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីទ្រព្យណាមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងបានបង់ពន្ធលើចំណេញមូលធនតាមច្បាប់ពន្ធដារបរទេសរួចហើយ ប្រសិនបើប្រាក់ពន្ធនៅបរទេសនោះ មានចំនួនតិចជាងប្រាក់ពន្ធដែលគណនាតាមប្រការ៩ ឬប្រការ១០ នៃប្រកាសនេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែម តែចំនួនលម្អៀងប៉ុណ្ណោះ។

**ប្រការ១៣ ..**

អ្នកជាប់ពន្ធត្រូវផ្តល់នូវឯកសារពាក់ព័ន្ធ សម្រាប់ការបង់ពន្ធលើចំណេញមូលធន ដូចខាងក្រោម៖

សម្រាប់ការលក់ឬផ្ទេរអចលនទ្រព្យ៖

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស។

២- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ។

៣- លិខិតបញ្ជាក់របស់អ្នកជាប់ពន្ធ អំពីការកំណត់និវាសនដ្ឋានជាគោលដើមរបស់ខ្លួន។

៤- បណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ឬឯកសារបញ្ជាក់ការទទួលស្គាល់របស់ស្ថាប័នមានសមត្ថកិច្ច។

៥- កិច្ចសន្យាទិញ-លក់ទ្រព្យ ឬកិច្ចសន្យាដោះដូរឬអំណោយ។

៦- វិក្កយបត្រទូទាត់ប្រាក់ និងវិក្កយបត្រចំណាយផ្សេងៗ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ។

៧- ឯកសារដទៃទៀតពាក់ព័ន្ធនឹងការលក់ឬផ្ទេរមូលធន។

សម្រាប់ការលក់ឬផ្ទេរ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស៖

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស។

២- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ។

៣- កិច្ចសន្យាទិញ-លក់ទ្រព្យឬផ្ទេរមូលធន ឬកិច្ចសន្យាផ្តល់អាជ្ញាបណ្ណពិសេស (Franchise Contract)។

៤- វិក្កយបត្រទូទាត់ប្រាក់ និងវិក្កយបត្រចំណាយផ្សេងៗ ដូចមានចែងក្នុងប្រការ៩ ឬប្រការ១០ នៃប្រកាសនេះ។

៥- ឯកសារដទៃទៀតពាក់ព័ន្ធនឹងការលក់ ឬផ្ទេរមូលធន។

**ប្រការ១៤ .-**

រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចត្រួតពិនិត្យ ដើម្បីធ្វើការកំណត់ឡើងវិញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ពន្ធដែលត្រូវបង់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៥ .-**

រាល់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មូលធនមិនមានលក្ខណៈគតិយុត្តគ្រប់គ្រាន់ទេ ក្នុងករណីដែលមូលធននោះមិនទាន់មានការបញ្ជាក់ពីការបង់ពន្ធលើចំណេញមូលធន។

**ប្រការ១៦ .-**

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការលក់ឬផ្ទេរមូលធន ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

**ប្រការ១៧ .-**

បុគ្គល ដែលជានិវាសនជននៃភាគីនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងចៀសវាងពន្ធជាមួយព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទប្បញ្ញត្តិទាក់ទិននឹងចំណេញមូលធន និងវិធាននិងនីតិវិធីពាក់ព័ន្ធការអនុវត្តកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងចៀសវាងពន្ធ។

**ប្រការ១៨ .-**

១- ពន្ធលើចំណេញមូលធនដែលសម្រេចបានពីការលក់ឬផ្ទេរ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះ-អាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស ត្រូវចាប់អនុវត្តលើចំណេញមូលធនដែលកើតមានឡើងចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នេះតទៅ។

២- ពន្ធលើចំណេញមូលធនដែលសម្រេចបានពីការលក់ឬផ្ទេរភាគហ៊ុនដោយប្រយោល ត្រូវអនុវត្តក្រោមបទប្បញ្ញត្តិដោយឡែក។

៣- ពន្ធលើចំណេញមូលធន ចំពោះអចលនទ្រព្យ ត្រូវចាប់អនុវត្តលើចំណេញមូលធនដែលកើតមានឡើងចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ តទៅ។

**ប្រការ១៩ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០..**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៩៩ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៥
## ស្តីពីពន្ធលើចំណេញមូលធន

### ការគណនាពន្ធលើចំណេញមូលធន

### ១. ការលក់ឬផ្ទេរអចលនទ្រព្យ

**ឧទាហរណ៍ ១ ៖ វិធីកាត់កងចំណាយតាមការកំណត់**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៨០០ ០០០ ០០០ រៀល។ លោក **ក** មិនបានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងផ្ទះល្វែងនោះ។ ដូចនេះ លោក **ក** អាចជ្រើសយកវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ៨០០ ០០០ ០០០ |
| ការកាត់កងចំណាយតាមការកំណត់ | = ៨០% x ចំណូលពីការលក់ឬផ្ទេរទ្រព្យ |
| | = ៨០% x ៨០០ ០០០ ០០០ |
| | = ៦៤០ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ចំណាយតាមការកំណត់ |
| | = ៨០០ ០០០ ០០០ - ៦៤០ ០០០ ០០០ |
| | = ១៦០ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ១៦០ ០០០ ០០០ x ២០% |
| | = ៣២ ០០០ ០០០ រៀល |

**ឧទាហរណ៍ ២ ៖ វិធីកាត់កងតាមចំណាយជាក់ស្តែង**

លោក **ក** បានលក់ផ្ទះមួយល្វែងទៅឱ្យលោក **ខ** ក្នុងតម្លៃ ៦០០ ០០០ ០០០ រៀល ដែលបានទិញក្នុងតម្លៃ ៤០០ ០០០ ០០០ រៀល ដោយបានបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនវត្ថុ ១៦ ០០០ ០០០ រៀល បានចំណាយកម្រៃជើងសាសម្រាប់ការលក់ផ្ទះ ២៤ ០០០ ០០០ រៀល និងបានចំណាយជួសជុលកែលម្អផ្ទះ ២០ ០០០ ០០០ រៀល។

លោក **ក** បានរក្សាទុកនូវឯកសារចំណាយនានាពាក់ព័ន្ធនឹងការកាន់កាប់ និងកែលម្អផ្ទះល្វែងនោះ។ ដូចនេះ លោក **ក** អាចជ្រើសយកវិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ៦០០ ០០០ ០០០ |
| ចំណាយជាក់ស្តែងសរុប | = ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ |
| | = ៤០០ ០០០ ០០០ + ១៦ ០០០ ០០០ + ២៤ ០០០ ០០០ + ២០ ០០០ ០០០ |
| | = ៤៦០ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប |
| | = ៦០០ ០០០ ០០០ - ៤៦០ ០០០ ០០០ |
| | = ១៤០ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូនធន x ២០% |
| | = ១៤០ ០០០ ០០០ x ២០% |
| | = ២៨ ០០០ ០០០ រៀល |

## ២. ការលក់ឬផ្ទេរគតិសន្យា

លោក **ក** បានទិញគតិសន្យាលើអចលនវត្ថុសម្រាប់រយៈពេល ១០ឆ្នាំ ក្នុងតម្លៃ ៣០០ ០០០ ០០០ រៀល។ នៅឆ្នាំដដែលនោះ លោក **ក** បានលក់គតិសន្យាលើអចលនវត្ថុនេះបន្ត ទៅឱ្យលោក **ខ** ក្នុងតម្លៃ ៤០០ ០០០ ០០០ រៀល។ លោក **ក** បានចំណាយលើការជួសជុលបន្ថែមអស់ចំនួន ២០ ០០០ ០០០ រៀល។

ដូចនេះ លោក **ក** ត្រូវប្រើប្រាស់វិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ៤០០ ០០០ ០០០ |
| ចំណាយជាក់ស្តែងសរុប | = ថ្លៃដើម + ចំណាយជួសជុល |
| | = ៣០០ ០០០ ០០០ + ២០ ០០០ ០០០ |
| | = ៣២០ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប |
| | = ៤០០ ០០០ ០០០ - ៣២០ ០០០ ០០០ |
| | = ៨០ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ៨០ ០០០ ០០០ x ២០% |
| | = ១៦ ០០០ ០០០ រៀល |

## ៣. ការលក់ឬផ្ទេរទ្រព្យវិនិយោគ (ភាគហ៊ុន)

លោក **ក** ជារូបវន្តបុគ្គលនិវាសនជន មានភាគហ៊ុនដែលមានតម្លៃ ៣០០ ០០០ ០០០ រៀល នៅក្នុងសហគ្រាស **ខ** ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ លោក **ក** បានលក់ភាគហ៊ុន ១០០% របស់ខ្លួន ទៅឱ្យលោក **គ** ជារូបវន្តបុគ្គលអនិវាសនជន ក្នុងតម្លៃ ១ ២៥០ ០០០ ០០០ រៀល ដោយធ្វើការចំណាយទាក់ទងនឹងប្រតិបត្តិការលក់ ១០ ០០០ ០០០ រៀល។ ដូចនេះ លោក **ក** ត្រូវប្រើប្រាស់វិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ១ ២៥០ ០០០ ០០០ |
| ថ្លៃដើមសម្រាប់កាត់កង | = មូលធនភាគហ៊ុនបានបង់ + ចំណាយទាក់ទងនឹងប្រតិបត្តិការលក់ |
| | = ៣០០ ០០០ ០០០ + ១០ ០០០ ០០០ |
| | = ៣១០ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ថ្លៃដើមសម្រាប់កាត់កង |
| | = ១ ២៥០ ០០០ ០០០ - ៣១០ ០០០ ០០០ |
| | = ៩៤០ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ៩៤០ ០០០ ០០០ x ២០% |
| | = ១៨៨ ០០០ ០០០ រៀល |

ករណីនេះ សហគ្រាស **ខ** ត្រូវមានកាតព្វកិច្ចប្រមូលប្រាក់ពន្ធលើចំណេញមូលធនពីលោក **ក** ហើយដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ។

## ៤. ការលក់ឬផ្ទេរកេរ្តិ៍ឈ្មោះអាជីវកម្ម (អាជ្ញាបណ្ណ)

លោក **ក** ទិញកិច្ចសន្យាផ្តល់អាជ្ញាបណ្ណពិសេស (Franchise Contract) ពីក្រុមហ៊ុន អាជីវកម្មកាហ្វេមួយក្នុងតម្លៃ ១០០ ០០០ ០០០ រៀលសម្រាប់រយៈពេល ៥ ឆ្នាំដែលអនុញ្ញាតឱ្យលោក **ក** អាចផ្ទេរកិច្ចសន្យាអាជ្ញាបណ្ណពិសេសនេះទៅអ្នកដទៃបាន។ លោក **ក** បានផ្ទេរកិច្ចសន្យាផ្តល់អាជ្ញាបណ្ណពិសេសនេះទៅឱ្យលោក **ខ** ក្នុងតម្លៃ ១២០ ០០០ ០០០ រៀលសម្រាប់រយៈពេល ៥ ឆ្នាំ។ លោក **ក** បានចំណាយលើសេវាផ្នែកច្បាប់ចំនួន ២ ០០០ ០០០ រៀល។ ដូចនេះ លោក **ក** ត្រូវប្រើប្រាស់វិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ១២០ ០០០ ០០០ |
| ចំណាយជាក់ស្តែងសរុប | = ថ្លៃដើម + ចំណាយសេវាផ្នែកច្បាប់ |
| | = ១០០ ០០០ ០០០ + ២ ០០០ ០០០ |
| | = ១០២ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប |
| | = ១២០ ០០០ ០០០ - ១០២ ០០០ ០០០ |
| | = ១៨ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ១៨ ០០០ ០០០ x ២០% |
| | = ៣ ៦០០ ០០០ រៀល |

## ៥. ការលក់ឬផ្ទេរកម្មសិទ្ធិបញ្ញា

លោក **ក** បានបង្កើតកម្មវិធីកុំព្យូទ័រ (Software) មួយដែលចំណាយថ្លៃដើមសរុបអស់ចំនួន ២០ ០០០ ០០០ រៀល និងចំណាយលើការចុះបញ្ជីកម្មសិទ្ធិបញ្ញាចំនួន ១ ០០០ ០០០ រៀល ហើយបានលក់សិទ្ធិលើកម្មវិធីកុំព្យូទ័រនេះទៅឱ្យសហគ្រាស **ខ** លើការប្រើប្រាស់កម្មវិធីក្នុងតម្លៃចំនួន ៥០ ០០០ ០០០ រៀល។ ដូចនេះ លោក **ក** ត្រូវប្រើប្រាស់វិធីកាត់កងតាមចំណាយជាក់ស្តែង ដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ៥០ ០០០ ០០០ |
| ចំណាយជាក់ស្តែងសរុប | = ថ្លៃដើម + ចំណាយលើការចុះបញ្ជីកម្មសិទ្ធិបញ្ញា |
| | = ២០ ០០០ ០០០ + ១ ០០០ ០០០ |
| | = ២១ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ចំណាយជាក់ស្តែងសរុប |
| | = ៥០ ០០០ ០០០ - ២១ ០០០ ០០០ |
| | = ២៩ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ២៩ ០០០ ០០០ x ២០% |
| | = ៥ ៨០០ ០០០ រៀល |

## ៦. ការលក់ឬផ្ទេររូបិយបណ្ណបរទេស

លោក **ក** បានទិញប្រាក់អឺរ៉ូចំនួន ២០០ ០០០ អឺរ៉ូ ដោយចំណាយអស់ ៨៥០ ០០០ ០០០ រៀល (១អឺរ៉ូ = ៤ ២៥០រៀល)។ មួយខែក្រោយមក គាត់បានលក់ចេញប្រាក់អឺរ៉ូនេះវិញ ដោយប្តូរបានជាប្រាក់រៀលបានចំនួន ៨៧០ ០០០ ០០០ រៀល (១អឺរ៉ូ = ៤ ៣៥០រៀល)។ ដូចនេះ លោក **ក** ត្រូវប្រើប្រាស់វិធីកាត់កងតាមចំណាយជាក់ស្តែងដែលត្រូវបានគណនាដូចខាងក្រោម៖

| | |
|---|---|
| ថ្លៃលក់ឬផ្ទេរទ្រព្យ | = ៨៧០ ០០០ ០០០ |
| ថ្លៃដើមនៃទ្រព្យ | = ៨៥០ ០០០ ០០០ |
| ចំណេញមូលធន | = ថ្លៃលក់ឬផ្ទេរទ្រព្យ - ថ្លៃដើមនៃទ្រព្យ |
| | = ៨៧០ ០០០ ០០០ - ៨៥០ ០០០ ០០០ |
| | = ២០ ០០០ ០០០ |
| ពន្ធលើចំណេញមូលធន | = ចំណេញមូលធន x ២០% |
| | = ២០ ០០០ ០០០ x ២០% |
| | = <u>៤ ០០០ ០០០ រៀល</u> |